00824867

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 19 / 07 / 2012
ម៉ោង (Time/Heure): 14:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E208/3

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង **សាធារណៈ / Public**

ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ២០១២

**ជូនចំពោះ:** **ភាគីនៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំឲ្យទទួលយកចម្លើយសាក្សីពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី ១ និងទី ២ (ឯកសារ E208 និងឯកសារ E208/2) និងចម្លើយតបរបស់ជនជាប់ចោទ អៀង សារី (E208/1)**

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើរបស់ការិយាល័យសហព្រះរាជអាជ្ញា ដែលស្នើសុំឲ្យទទួលយកចម្លើយជាលាយលក្ខណ៍អក្សរនានា ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី ១ និងដំណាក់កាលទី ២ ដូចមានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ (ឯកសារ E208 និងឯកសារ E208/2 ដាច់ដោយឡែកពីគ្នា) និងចម្លើយតបទៅនឹងសំណើ E208 របស់មេធាវីការពារជនជាប់ចោទ អៀង សារី ដែលក្នុងនោះមេធាវីការពារជនជាប់បានបង្ហាញចេតនាក្នុងការជំទាស់ទៅនឹងការទទួលយកចម្លើយមួយចំនួនក្នុងចំណោមចម្លើយទាំងនេះ ( ឯកសារ E208/1)។

២. ក្នុងសេចក្តីសម្រេច E96/7របស់ខ្លួន ដែលបានចេញឆាប់ៗបន្ទាប់ពីការដាក់ឯកសារ E208 ទៅក្នុងសំណុំរឿង អង្គជំនុំជម្រះបានលើកឡើងអំពីលក្ខខណ្ឌដែលគ្របដណ្តប់លើការដាក់នៅ

ចំពោះមុខអង្គជំនុំជម្រះនូវចម្លើយជាលាយលក្ខណ៍អក្សរ និងទម្រង់នីតិវិធីដែលត្រូវបំពេញដោយភាគីដែលស្នើសុំឲ្យមានការទទួលយកចម្លើយទាំងនេះ ដោយអនុលោមតាមសេចក្ដីសម្រេចនេះ។ ចំណុចនេះរួមបញ្ចូលទាំងលក្ខខណ្ឌមួយដែលតម្រូវឲ្យភាគីដែលស្នើសុំដាក់ចម្លើយជាលាយលក្ខណ៍អក្សរនៅចំពោះមុខអង្គជំនុំជម្រះ បង្ហាញអំពីគោលបំណងនៃភស្តុតាងដែលចម្លើយទាំងនោះត្រូវបានស្នើសុំ ឲ្យបានត្រឹមថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២។ អង្គជំនុំជម្រះសូមជូនដំណឹងទៀតថាខ្លួននឹងកំណត់កាលបរិច្ឆេទនៃសវនាការ ឬផ្ដល់ឱកាសដើម្បីដាក់សេចក្ដីជំទាស់ពាក់ព័ន្ធណាមួយទៅនឹងឯកសារ ដែលភាគីបានស្នើសុំឲ្យមានការទទួលយកដោយអនុលោមតាមសេចក្ដីសម្រេចនេះ (ឯកសារ E96/7,កថាខណ្ឌ ៣៣-៣៦)។ ក្នុងសំណើ E208/2 របស់ខ្លួន ការិយាល័យសហព្រះរាជអាជ្ញាគូសបញ្ជាក់ថាចម្លើយជាលាយលក្ខណ៍អក្សរដែលភ្ជាប់ទៅនឹងសំណើទាំង២របស់ខ្លួន ស្របជាមួយលក្ខខណ្ឌសម្រាប់ការទទួលយកជាភស្តុតាងដូចមានចែងក្នុងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ E96/7។

៣. ដើម្បីផលប្រយោជន៍នៃប្រសិទ្ធភាពសវនាការ អង្គជំនុំជម្រះមានបំណងដាក់បញ្ចូលគ្នាឲ្យបានច្រើនតាមលទ្ធភាពដែលអាចធ្វើទៅបាន នូវចម្លើយជាលាយលក្ខណ៍អក្សរទាំងអស់ ដែលភាគីបានស្នើសុំឲ្យមានការទទួលយកធ្វើជាភស្តុតាង ដែលពាក់ព័ន្ធទៅនឹងផ្នែកភស្តុតាងទាំងឡាយដែលនៅសេសសល់ក្នុងសំណុំរឿង០០២/០១ (*ឧទាហរណ៍* ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២) ដោយចម្លើយទាំងនេះត្រូវបានពិចារណាក្នុងសេចក្ដីសម្រេច E96/7។ ហេតុដូច្នេះ អង្គជំនុំជម្រះស្នើភាគីទាំងអស់បញ្ជាក់ដោយយោងតាមលក្ខខណ្ឌតម្រូវ និងនីតិវិធីដូចមានចែងក្នុងសេចក្ដីសម្រេច E96/7 អំពីចម្លើយជាលាយលក្ខណ៍អក្សរទាំងនោះពីបញ្ជីឯកសាររបស់ខ្លួនដែលបានដាក់ចូលក្នុងសំណុំរឿងកាលពីខែ មេសា ឆ្នាំ ២០១១ ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី ១ និងទី ២ មិនឲ្យហួសពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២។ ភាគីអាចជូនដំណឹងមកមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ប្រសិនបើខ្លួនយល់ឃើញថាជាការចាំបាច់ដែលត្រូវពន្យារពេលវេលាកំណត់ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២ សម្រាប់ការដាក់ចម្លើយទាំងអស់នេះដែលបន្ទាប់ពីនោះនឹងមានសេចក្ដីណែនាំបន្ថែម (ពាក់ព័ន្ធនឹងពេលវេលាកំណត់សម្រាប់ការដាក់ចម្លើយ និងសម្រាប់ការដាក់សេចក្ដីជំទាស់នានាប្រសិនបើមានទៅនឹងឯកសារដែលភាគីផ្សេងៗបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ)។ នៅក្នុងពេលសមស្របខាងមុខនេះ អង្គជំនុំជម្រះនឹងផ្ដល់សេចក្ដីណែនាំ

ដល់ភាគីអំពីការដាក់ឯកសារ និងភស្តុតាងនានា ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី ១ និងទី ២។

៤. អនុស្សរណៈនេះជាចម្លើយជាផ្លូវការរបស់អង្គជំនុំជម្រះតបទៅនឹងសំណើ E208 និងសំណើ E208/2 ព្រមទាំងចម្លើយតប E208/1។